# លិខិតការចូលរួមក្នុងការអប់រំពិសេសផ្នែកសាសនា និងការអប់រំពិសេសផ្នែកសីលធម៌

លក្ខណៈពិសេសនៃប្រព័ន្ធអប់រំសាធារណៈក្នុងរដ្ឋ NSW គឺឱកាសដើម្បីផ្តល់នូវពេលវេលាក្នុងថ្នាក់រៀនសម្រាប់ការអប់រំផ្នែកសីលធម៌ ជំនឿ និងចរិយាធម៌ ពីទស្សនវិស័យសាសនា ឬមិនមែនសាសនា ទៅតាមជម្រើសរបស់ឪពុកម្តាយ/អ្នកថែទាំ។

គេហទំព័ររបស់សាលារៀន (តំណភ្ជាប់ដូចបង្ហាញខាងក្រោម) ផ្តល់ជូនព័ត៌មានអំពីជម្រើសទាំងនេះ ដើម្បីគាំទ្រជម្រើសរបស់ឪពុកម្តាយ/អ្នកថែទាំ។

________________________________________

តំណភ្ជាប់គេហទំព័ររបស់សាលារៀន

នៅពេលណាក៏បាន ឪពុកម្តាយ/អ្នកថែទាំអាចជូនដំណឹងជាលាយលក្ខណ៍អក្សរដល់សាលារៀន ដែលថាពួកគេប្រាថ្នាចង់ផ្លាស់ប្តូរការសម្រេចចិត្តរបស់ពួកគេ។ សិស្សនឹងបន្តការរៀបចំដូចគ្នានឹងឆ្នាំមុនដែរ លុះត្រាតែឪពុកម្តាយ/អ្នកថែទាំ បានស្នើសុំការផ្លាស់ប្តូរជាលាយលក្ខណ៍អក្សរ។

ប្រសិនបើជម្រើសការអប់រំពិសេសផ្នែកសាសនា (Special Religious Education (SRE)) ឬការអប់រំពិសេសផ្នែកសីលធម៌ (Special Education in Ethics (SEE)) របស់អ្នកមិនមានផ្តល់ជូនទេ សូមទាក់ទងអ្នកផ្តល់សេវាកម្មដែលបានយល់ព្រម។ សិស្សដែលមិនចូលរួមក្នុងការអប់រំពិសេសផ្នែកសាសនា ឬការអប់រំពិសេសផ្នែកសីលធម៌ត្រូវបានផ្តល់នូវសកម្មភាពនានា ដែលមានអត្ថន័យជំនួសផ្សេងទៀតក្រោមការត្រួតពិនិត្យ។

សម្រាប់ព័ត៌មានបន្ថែមអំពីការអប់រំពិសេសផ្នែកសាសនា និងការអប់រំពិសេសផ្នែកសីលធម៌ រួមទាំងបញ្ជីអ្នកផ្តល់សេវាកម្មដែលបានយល់ព្រម សូមមើល៖ សាសនា និងសីលធម៌

________________________________________

ឈ្មោះសាលារៀន

ជម្រើសខាងក្រោមមានផ្តល់ជូននៅសាលារៀនដែលមានឈ្មោះខាងលើ។ សូមជ្រើសរើសជម្រើសមួយ ប្រសិនបើអ្នកចង់ឱ្យកូនរបស់អ្នកចូលរួម SRE ហើយគូសប្រអប់នៅក្បែរជម្រើសរបស់អ្នក។

## ជម្រើស SRE (SRE Options)

☐ ជម្រើសទី 1 ____________________

☐ ជម្រើសទី 2 ____________________

☐ ជម្រើសទី 3 ____________________

☐ ជម្រើសទី 4 ____________________

☐ ជម្រើសទី 5 ____________________

☐ ជម្រើសទី 6 ____________________

☐ ជម្រើសទី 7 ____________________

ឬ

☐ សូមគូសប្រអប់នេះ ប្រសិនបើអ្នកមិនចង់ឱ្យកូនរបស់អ្នកចូលរួម SRE។
(Student will not participate in SRE)

**សូមបំពេញព័ត៌មានខាងក្រោមជាភាសាអង់គ្លេស ចុះហត្ថលេខា ហើយបញ្ជូនលិខិតនេះទៅឱ្យសាលារៀនវិញ។**

ឈ្មោះសិស្ស ______________________ ឆ្នាំសិក្សា __________

Student name | Year

ហត្ថលេខារបស់ឪពុកម្ដាយ/អ្នកថែទាំ ______________________ កាលបរិច្ឆេទ __________

Signature of parent/carer | Date

## សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកចង់បានព័ត៌មានបន្ថែម ហើយអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ សូមទូរសព្ទទៅសេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ តាមលេខ 131 450 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។ សូមប្រាប់ការីទូរសព្ទនូវលេខទូរសព្ទដែលអ្នកចង់ហៅ ហើយការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ ដើម្បីជួយក្នុងការសន្ទនារបស់អ្នក។ អ្នកនឹងមិនត្រូវគេគិតថ្លៃសម្រាប់សេវាកម្មនេះទេ។

ប្រសិនបើអ្នកបានជ្រើសរើសការអប់រំពិសេសផ្នែកសាសនា និងការអប់រំពិសេសផ្នែកសីលធម៌ ក្នុងការធ្វើដូច្នេះអ្នកបញ្ជាក់ថា អ្នកយល់ព្រមឱ្យក្រសួងផ្ដល់ឈ្មោះកូនរបស់អ្នកទៅអ្នកផ្ដល់សេវាកម្មដែលបានតែងតាំងហើយ។ ក្រសួងត្រូវបានតម្រូវឱ្យទទួលបានការយល់ព្រមពីអ្នកក្រោមផ្នែក 26 នៃច្បាប់ឯកជនភាព និងការការពារព័ត៌មានផ្ទាល់ខ្លួន ឆ្នាំ 1998 (NSW) ដូច្នេះក្រសួងមិនចាំបាច់គោរពតាមផ្នែក19 ដែលនឹងអនុវត្តផ្សេងពីនេះ ដើម្បីទប់ស្កាត់ក្រសួងពីការផ្ដល់ឈ្មោះកូនរបស់អ្នក។